**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

សេចក្តីប្រកាសព័ត៌មាន

## «កម្ពុជា និងដូមីនីក ប្តេជ្ញាពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី»

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២៣ - **ឯកឧត្តមបណ្ឌិត វីន ហេនដឺសាន់** (Vince Henderson) រដ្ឋមន្ត្រីការបរទេស ធុរកិច្ចអន្តរជាតិ ពាណិជ្ជកម្ម និងថាមពល នៃប្រទេសកុំមិនវែលដូមីនីក បានបញ្ចប់ដំណើរទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២២-២៤ ខែមីនា ឆ្នាំ២០២៣។

ក្នុងកិច្ចប្រជុំទ្វេភាគី នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម អ៊ុច បូរិទ្ធ** រដ្ឋមន្ត្រីស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ឯកឧត្តមបណ្ឌិត **វីន ហេនដឺសាន់** បានអះអាងអំពីការប្តេជ្ញាចិត្តក្នុងការពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។

ឯកឧត្តមរដ្ឋមន្ត្រីស្តីទី បានជម្រាបជូនអំពីស្ថានភាពនយោបាយ និងសេដ្ឋកិច្ច រួមទាំងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការសម្រេចនិងរក្សាបាននូវសន្តិភាពនិងស្ថិរភាពដែលរកបានយ៉ាងលំបាក លិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ ឯកឧត្តមក៏បានជម្រាបជូនផងដែរ នូវមុខទំនិញសក្តានុពលមួយចំនួនសម្រាប់ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ក៏ដូចជាការលើកទឹកចិត្តជាច្រើនសម្រាប់វិនិយោគិន នៅក្រោមច្បាប់វិនិយោគថ្មីរបស់កម្ពុជា ។

ឯកឧត្តមរដ្ឋមន្ត្រី ហេនដឺសាន់ បានកោតសរសើរចំពោះកម្រិតនៃការអភិវឌ្ឍរបស់កម្ពុជា និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ទទួលបានដោយសារសន្តិភាពនិងស្ថិរភាព ដែលកម្ពុជាបានថែរក្សា។ ឯកឧត្តមរដ្ឋមន្ត្រី បានឯកភាពចំពោះគន្លឹះនៃការអភិវឌ្ឍគឺសន្តិភាពនិងស្ថិរភាព និងបញ្ហាប្រឈមនានាដែលរដ្ឋតូចៗជួបប្រទះ ក្នុងបរិបទការប្រកួតប្រជែងរវាងមហាអំណាច។

ភាគីទាំងពីរបានពិភាក្សាអំពីវិធីសាស្រ្ត និងមធ្យោបាយនានា ដើម្បីស្វែងរកសក្តានុពលនានាក្នុងវិស័យមួយចំនួនដែលមានផលប្រយោជន៍រួម ដូចជា ពាណិជ្ជកម្មនិងការវិនិយោគ កសិកម្ម ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទេសចរណ៍ធម្មជាតិ និងបដិសណ្ឋារកិច្ច ជាដើម។ ភាគីទាំងពីរបានឯកភាពជាគោលការណ៍ អំពីលទ្ធភាពនៃការបង្កើតយន្តការពិគ្រោះយោបល់ទ្វេភាគី រវាង

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ក្រសួងការបរទេសនៃប្រទេសទាំងពីរ និងបានឯកភាពគាំទ្រគ្នាទៅវិញទៅមក នៅក្នុងវេទិកាពហុភាគី ជាពិសេស ប្រព័ន្ធអង្គការសហប្រជាជាតិ។

បន្ទាប់ពីកិច្ចពិភាក្សា ឯកឧត្តម អ៊ុច បូរិទ្ធ និង ឯកឧត្តមបណ្ឌិត វីន ហេនជីសាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសកុំមិនវែលដូមីនីក ស្តីពីការលើកលែងទិដ្ឋាការ សម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូតនិងផ្លូវការ។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត វីន ហេនជីសាន់ បានចូលជួបសម្តែងការគួរសមជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងឱកាសនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចាត់ទុកដំណើរទស្សនកិច្ចជាលើកដំបូងរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេសនាពេលនេះ ជាការចាប់ផ្តើមដ៏ល្អមួយ ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក បន្ទាប់ពីប្រទេសទាំងពីរបានបង្កើតទំនាក់ទំនងការទូត អស់រយៈពេល១៣ឆ្នាំកន្លងមក។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូតនិងផ្លូវការ ដែលនឹងបើកផ្លូវឱ្យមានកិច្ចសន្ទនាបន្ថែមទៀត ព្រមទាំងបានលើកឡើងពីវិស័យសំខាន់ៗមួយចំនួននៃកិច្ចសហប្រតិបត្តិការសក្តានុពល រួមមាន វិស័យកសិកម្ម នេសាទ និងទេសចរណ៍ ដែលប្រទេសទាំងពីរអាចផ្លាស់ប្តូរបទពិសោធន៍រវាងគ្នានិងគ្នា។

ដោយស្ញប់ស្ញែងពីភាពរីកចម្រើនរបស់កម្ពុជា ឯកឧត្តមបណ្ឌិត វីន ហេនជីសាន់ បានកោតសរសើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះភាពសាមញ្ញ ប៉ុន្តែម៉ឺងម៉ាត់ ក្នុងការនាំមកនូវសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរបស់កម្ពុជា ព្រមទាំងបានសង្កត់ធ្ងន់ថា **សម្តេចតេជោ** មានបទពិសោធន៍ជាច្រើន ដើម្បីចែករំលែកទៅកាន់ពិភពលោក។ ឯកឧត្តមរដ្ឋមន្ត្រីការបរទេស បានយល់ស្របចំពោះទស្សនវិស័យនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យខាងលើ និងត្រៀមខ្លួនពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ព្រមទាំងបានស្ម័គ្រចិត្តធ្វើជាច្រកទំនាក់ទំនងសម្រាប់កម្ពុជា ទៅកាន់ប្រទេសផ្សេងទៀត នៅតំបន់ការាបៀន។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងឯកឧត្តមបណ្ឌិត វីន ហេនជីសាន់ បានយល់ស្របចំពោះទស្សនៈថា រដ្ឋតូចៗផ្តល់សារសំខាន់យ៉ាងខ្លាំងចំពោះប្រព័ន្ធអន្តរជាតិដែលផ្អែកលើច្បាប់ និងបានឯកភាពគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌពហុភាគី ជាពិសេស នៅអង្គការសហប្រជាជាតិ៕